# 3. វិធីដើម្បីទទួលបានការថែទាំ

## ការថែទាំដោយមានការគិតគូរ

### សេវាស្ដីពីការយល់ព្រមសម្រាប់អនីតិជន

ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ អ្នកអាចទទួលបានសេវាមួយចំនួនដោយមិនមានការអនុញ្ញាតពីឪពុកម្ដាយ ឬអាណាព្យាបាល។ សេវាទាំងនេះត្រូវបានហៅថាសេវាស្ដីពីការយល់ព្រមសម្រាប់អនីតិជន។

អ្នកអាចទទួលបានសេវាទាំងនេះដោយគ្មានការអនុញ្ញាតពីឪពុកម្ដាយ ឬអាណាព្យាបាលរបស់អ្នក៖

- **សេវាសម្រាប់ការចាប់រំលោភ និងការរំលោភបំពានផ្លូវភេទផ្សេងៗទៀត**
- **ការធ្វើតេស្ត និងការប្រឹក្សាអំពី**ការមានផ្ទៃពោះ
- **សេវាការពារមិនឱ្យមានកូនដូចជា**ការគ្រប់គ្រងកំណើត **(មិនរាប់បញ្ចូលការក្រៀវ)**
- សេវារំលូតកូន

ប្រសិនបើអ្នកមានអាយុ 12 ឆ្នាំ ឬចាស់ជាងនេះ អ្នកក៏អាចទទួលបាន
សេវាទាំងនេះដោយគ្មានការអនុញ្ញាតពីឪពុកម្ដាយ ឬអាណាព្យាបាលរបស់អ្នក៖

- សេវាសុខភាពផ្លូវចិត្តរបស់អ្នកជំងឺមិននៅសម្រាកព្យាបាល ដោយផ្អែកលើកម្រិតនៃភាពចាស់ទុំរបស់អ្នក និងសមត្ថភាពក្នុងការចូលរួមក្នុងការថែទាំសុខភាពផ្ទាល់ខ្លួនរបស់អ្នក។
- **ការប្រឹក្សា** ការបង្ការ ការធ្វើតេស្ត និងការព្យាបាល HIV/AIDS
- ការបង្ការ ការធ្វើតេស្ត និងការព្យាបាលការឆ្លងជំងឺកាមរោគ **ដែលអាច រាប់បញ្ចូលទាំងជំងឺកាមរោគដូចជា រោគស្វាយ ប្រមេះទឹកបាយ ជំងឺក្លាមីឌា និងជំងឺពងបែកលើប្រដាប់ភេទ។**
- ការព្យាបាលជំងឺដែលបណ្ដាលមកពីការប្រើសារធាតុញៀន **សម្រាប់ការសេបគ្រឿងញៀន និងគ្រឿងស្រវឹង រួមទាំងការពិនិត្យ ការវាយតម្លៃ អន្តរាគមន៍ និងសេវាបញ្ជូនបន្ត**
  - ដើម្បីស្វែងយល់បន្ថែម សូមអាន "សេវាព្យាបាលជំងឺដែលបណ្ដាលមកពីការប្រើសារធាតុញៀន" នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំនេះ។

សម្រាប់ការធ្វើតេស្តការមានផ្ទៃពោះ សេវារៀបចំផែនការគ្រួសារ សេវាពន្យារកំណើត ឬសេវាសម្រាប់ការឆ្លងជំងឺកាមរោគ វេជ្ជបណ្ឌិត ឬគ្លីនិកមិនចាំបាច់ស្ថិតនៅក្នុងបណ្តាញរបស់ Molina Healthcare ទេ។ អ្នកអាចជ្រើសរើសអ្នកផ្តល់សេវា Medi-Cal ណាម្នាក់ រួចទៅកាន់ពួកគេ ដើម្បីទទួលបានសេវាទាំងនេះដោយមិនចាំបាច់មានការបញ្ជូនបន្ត ឬការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)។ **សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងសេវារៀបចំផែនការគ្រួសារ សូមមើល "សេវាសុខភាព និងការបង្ការ និងការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ" នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំនេះ។**

សម្រាប់សេវាស្តីពីការយល់ព្រមសម្រាប់អនីតិជនដែលជាសេវាសុខភាពផ្លូវចិត្ត**អ្នកជំងឺមិននៅសម្រាកព្យាបាល** អ្នកអាចទៅជួបអ្នកផ្តល់សេវាក្នុងបណ្តាញ **ឬក្រៅបណ្តាញ-** ដោយគ្មានការបញ្ជូនបន្ត និងដោយគ្មានការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)។ PCP របស់អ្នកមិនចាំបាច់បញ្ជូនអ្នកទេ ហើយអ្នកមិនចាំបាច់ទទួលបានការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ពី Molina Healthcare ដើម្បីទទួលបានសេវាស្តីពីការយល់ព្រមសម្រាប់អនីតិជនដែលមានការធានារ៉ាប់រង។

សេវាស្តីពីការយល់ព្រមសម្រាប់អនីតិជនដែលជាសេវាសុខភាពផ្លូវចិត្តពិសេសមិនត្រូវបានធានារ៉ាប់រងទេ។ សេវាសុខភាពផ្លូវចិត្តពិសេសត្រូវបានធានារ៉ាប់រងដោយគម្រោងសុខភាពផ្លូវចិត្តរបស់ខោនធីសម្រាប់ខោនធីដែលអ្នករស់នៅ។

អនីតិជនអាចពិភាក្សាជាមួយអ្នកតំណាងជាលក្ខណៈឯកជនអំពីកង្វល់ស្តីពីសុខភាពរបស់ពួកគេដោយទូរសព្ទទៅខ្សែទូរសព្ទប្រឹក្សាគិលានុបដ្ឋាក 24/7 ដោយទូរសព្ទទៅលេខ 1-888-275-8750 (ភាសាអង់គ្លេស) ឬ 1-866-648-3537 (ភាសាអេស្ប៉ាញ)។

Molina Healthcare នឹងមិនផ្ញើព័ត៌មានអំពីការទទួលបានសេវាដែលមានការគិតគូរដល់ឪពុកម្តាយ ឬអាណាព្យាបាលឡើយ។
ដើម្បីស្វែងយល់បន្ថែមអំពីរបៀបស្នើសុំទំនាក់ទំនងសម្ងាត់ទាក់ទងនឹងសេវាដែលមានការគិតគូរ សូមអាន "សេចក្តីជូនដំណឹងអំពីការអនុវត្តស្តីពីឯកជនភាព" នៅក្នុងជំពូកទី 7 នៃសៀវភៅណែនាំនេះ។

# 4. អត្ថប្រយោជន៍ និងសេវា

## អ្វីដែលគម្រោងសុខភាពរបស់អ្នកធានារ៉ាប់រង

ជំពូកនេះពន្យល់អំពីសេវារ៉ាប់រងរបស់អ្នកក្នុងនាមជាសមាជិកនៃ Molina Healthcare។ សេវាដែលមានការធានារ៉ាប់រងរបស់អ្នក គឺមិនគិតថ្លៃទេ ដរាបណាវាចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងផ្តល់ដោយអ្នកផ្តល់សេវាក្នុងបណ្តាញ។ អ្នកត្រូវតែស្នើសុំការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ពីយើង ប្រសិនបើការថែទាំស្ថិតនៅក្រៅបណ្តាញ លើកលែងតែសេវាដែលមានការគិតគូរមួយចំនួន និងការថែទាំសង្គ្រោះបន្ទាន់។ ការថែទាំបន្ទាន់នៅក្រៅតំបន់ត្រូវបានធានារ៉ាប់រង នៅពេលអ្នកស្ថិតនៅក្នុងតំបន់ដែលយើងមិនផ្តល់សេវា។ គម្រោងសុខភាពរបស់អ្នកអាចធានារ៉ាប់រងលើសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រពីអ្នកផ្តល់សេវាក្រៅបណ្តាញ ប៉ុន្តែអ្នកត្រូវតែស្នើសុំ Molina Healthcare នូវការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) សម្រាប់រឿងនេះ។

សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រគឺសមហេតុផល និងចាំបាច់ដើម្បីការពារអាយុជីវិតរបស់អ្នក ការពារអ្នកពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ឬពិការ ឬកាត់បន្ថយការឈឺចាប់ធ្ងន់ធ្ងរពីជំងឺ ជំងឺ ឬរបួស។ សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ សេវា Medi-Cal រួមមានការថែទាំដែលចាំបាច់ផ្នែកវេជ្ជសាស្ត្រដើម្បីជួសជុល ឬជួយសម្រាលជំងឺ ឬស្ថានភាពផ្លូវកាយ ឬផ្លូវចិត្ត។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាដែលមានការធានារ៉ាប់រងរបស់អ្នក សូមទូរសព្ទទៅ 1-888-665-4621 (TTY/TDD ឬ 711)។

សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ ទទួលបានអត្ថប្រយោជន៍ និងសេវាបន្ថែម។ ដើម្បីស្វែងយល់បន្ថែម សូមអានជំពូកទី 5 “ការថែទាំកុមារ និងយុវជន”។

អត្ថប្រយោជន៍សុខភាពជាមូលដ្ឋានមួយចំនួនដែល Molina Healthcare ផ្តល់ជូនត្រូវបានរាយខាងក្រោម។ អត្ថប្រយោជន៍ដែលមានផ្កាយ (*) មួយ ត្រូវការការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន)។

- ការចាក់ម្ជុលវិជ្ជាសាស្ត្រ*
- ការព្យាបាលជំងឺស្រួចស្រាវ (ការព្យាបាលរយៈពេលខ្លី) និងសេវាថែទាំសុខភាពតាមផ្ទះ
- ការចាក់ថ្នាំបង្ការសម្រាប់មនុស្សពេញវ័យ
- ការធ្វើតេស្តអាឡែរហ្ស៊ី និងការចាក់ថ្នាំ
- សេវារថយន្តសង្គ្រោះបន្ទាន់សម្រាប់ការសង្គ្រោះបន្ទាន់
- សេវាអ្នកជំនាញខាងថ្នាំសន្លប់
- ការបង្ការជំងឺហឺត
- សោតទស្សន៍*
- ការព្យាបាលរោគធាត់ពេក*
- ការព្យាបាលសុខភាពអាកប្បកិរិយា*
- ការស្តានីតិសម្បទាបេះដូង
- សេវាព្យាបាលតាមបែបចលនា*
- ការព្យាបាលដោយប្រើគីមី និងការព្យាបាលដោយវិទ្យុសកម្ម
- ការវាយតម្លៃសុខភាពការយល់ដឹង
- សេវាបុគ្គលិកសុខាភិបាលសហគមន៍
- សេវាទន្តសាស្ត្រ - មានកំណត់ (អនុវត្តដោយគ្រូពេទ្យជំនាញ/អ្នកផ្តល់សេវាថែទាំបឋម (PCP) នៅក្នុងការិយាល័យពេទ្យ
- សេវាលាងឈាម/លាងឈាមដោយម៉ាស៊ីន
- សេវាអ្នកទំនុកបម្រុងម្តាយទារក
- ឧបករណ៍វេជ្ជសាស្ត្រប្រើប្រាស់បានយូរ (DME)*
- សេវាព្យាបាលជាក្រុមពីរនាក់
- ការទៅកាន់បន្ទប់សង្គ្រោះបន្ទាន់
- អាហារូបត្ថម្ភបញ្ចូលតាមទុយោចូលតាមមាត់ និងចូលតាមរាងកាយ*
- ការប្រឹក្សា និងការទៅកាន់ការិយាល័យរៀបចំផែនការគ្រួសារ (អ្នកអាចទៅកាន់អ្នកផ្តល់សេវាដែលមិនចូលរួម)
- សេវា និងឧបករណ៍និតិសម្បទា*
- ឧបករណ៍ជំនួយការស្តាប់
- ការថែទាំសុខភាពតាមផ្ទះ*
- ការថែទាំនៅសង្គហដ្ឋាន*
- ការថែទាំព្យាបាល និងវះកាត់អ្នកជំងឺនៅសម្រាកព្យាបាល*
- មន្ទីរពិសោធន៍ និងវិទ្យុសកម្ម*
- ការព្យាបាល និងសេវាសុខភាពតាមផ្ទះរយៈពេលវែង*
- ការថែទាំសម្ភព និងទារកទើបនឹងកើត
- ការប្តូរសរីរាង្គសំខាន់ៗ*
- ការព្យាបាលស្តារនីតិសម្បទារ*
- ឧបករណ៍ជួយទ្រ (Orthotic) / សិរីរាង្គសិប្បនិម្មិត (Prosthetic)*
- សម្ភារផ្គត់ផ្គង់ការវះកាត់បើកផ្លូវចូលទៅក្នុងពោះវៀនធំ (ostomy) និងផ្លូវម៉ូត្រ
- សេវាមន្ទីរពេទ្យអ្នកជំងឺមិននៅសម្រាកព្យាបាល
- សេវាសុខភាពផ្លូវចិត្តរបស់អ្នកជំងឺមិននៅសម្រាកព្យាបាល
- ការវះកាត់អ្នកជំងឺមិននៅសម្រាកព្យាបាល*
- ការថែទាំបំបាត់ការឈឺចាប់បណ្តោះអាសន្ន*
- ការទៅជួប PCP
- សេវាសម្រាប់កុមារ
- ការព្យាបាលដោយចលនា*
- សេវាបាទាវិជ្ជាសាស្ត្រ (Podiatry)*
- ការស្តារនីតិសម្បទាសួត
- ការកំណត់លំដាប់សេណូមទាំងមូលយ៉ាងឆាប់រហ័ស
- ឧបករណ៍ និងសេវាស្តារនីតិសម្បទា*
- សេវាថែទាំជំនាញ
- ការទៅជួបអ្នកឯកទេស
- ការព្យាបាលការនិយាយ*
- សេវាវះកាត់
- ការផ្តល់សេវាសុខភាពពីចម្ងាយ/ទូរសុខភាព
- សេវាប្តូរភេទ*
- ការថែទាំបន្ទាន់
- សេវាផ្នែកចក្ខុ*
- សេវាសុខភាពស្ត្រី

# អត្ថប្រយោជន៍ Medi-Cal ធានារ៉ាប់រងដោយ Molina Healthcare

## ការថែទាំសម្ភព និងទារកទើបនឹងកើត

Molina Healthcare ធានារ៉ាប់រងលើសេវាថែទាំសម្ភព និងទារកទើបនឹងកើតទាំងនេះ៖

- សេវាមជ្ឈមណ្ឌលសម្រាលកូន
- ម៉ាស៊ីនបូមទឹកដោះ និងសម្ភារផ្គត់ផ្គង់
- ជំនួយ និងការអប់រំការបំបៅកូនដោយទឹកដោះម្ដាយ
- **ការសម្របសម្រួលការថែទាំ**
- ឆ្មបគិលានុបដ្ឋាកដែលមានវិញ្ញាបនបត្រ (CNM)
- **ការប្រឹក្សាយោបល់**
- ការសម្រាលកូន និងការថែទាំក្រោយសម្រាល
- ការធ្វើរោគវិនិច្ឆ័យជំងឺហ្សែនរបស់គភ៌ និងការប្រឹក្សា
- សេវាអ្នកទំនុកបម្រុងម្ដាយទារក
- ឆ្មបដែលមានអាជ្ញាបណ្ណ (LM)
- សេវាសុខភាពផ្លូវចិត្តរបស់មាតា
- ការថែទាំទារកទើបនឹងកើត
- **ការអប់រំអំពីអាហារូបត្ថម្ភ**
- ការអប់រំសុខភាពដែលទាក់ទងនឹងការមានផ្ទៃពោះ
- ការថែទាំមុនពេលសម្រាល
- **ការវាយតម្លៃសុខភាពសង្គម និងផ្លូវចិត្ត និងការបញ្ជូនបន្ត**
- **អាហារបំប៉នវីតាមីន និងសារធាតុរ៉ែ**